**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ រវាងប្រតិភូបុគ្គលិក និងនិយោជក នៃសហគ្រាស ស៊ីវ៉ាយ-អេសអរ ហូថេល ហ្គ្រេន ឡាយអិន ឯ.ក

ប្រតិភូបុគ្គលិកបានព្រមព្រៀងលើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១២៨ នាក់ រយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ ដោយសារវិបត្តិជម្ងឺកូវីដ១៩ ដែលធ្វើអោយផ្អាកដំណើរការអាជីវកម្ម។

ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងតាមសេចក្តីកំណត់ដូចជា ផ្តល់ជូនប្រាក់ខែគោល ៤០%សម្រាប់ថ្នាក់ដឹកនាំកម្រិតយ៉ែលឡូ ថ្នាក់ដឹកនាំកម្រិតភឺភល ថ្នាក់ដឹកនាំកម្រិតប្លូ ថ្នាក់ដឹកនាំកម្រិតរ៉េដ និងថ្នាក់ដឹកនាំកម្រិត៤ដែលមានប្រាក់ខែគោលចាប់ពី៦៥០ដុល្លាអាមេរិចឡើង និង៥០% សម្រាប់បុគ្គលិកកម្រិត៤ដែលមានប្រាក់ខែគោលចាប់ពី៦៤៩ដុល្លាចុះរហូតដល់ថ្នាក់ក្រោម។ អំឡុងពេលបិទសណ្ឋាគារ កម្មករនិយោជិតត្រូវមានវត្តមាននៅកន្លែងធ្វើការ និងអនុវត្តការងារតាមកាលវិភាគដែលបានកំណត់ដោយប្រធានផ្នែករៀងៗខ្លួន។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
សៀមរាប ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០

ប្រតិភូបុគ្គលិក

**សាន ណារិទ្ធ**

តំណាងនិយោជក
ជ. នាយិកាចាត់ការទូទៅ
ប្រធានធនធានមនុស្ស

CY-SR HOTEL GRAND LION CO.,LTD.
KINGDOM OF CAMBODIA

**ស៊ិន សុរស់**